ADB ASIAN DEVELOPMENT BANK

# ប្រទេសកម្ពុជា៖ កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ ទី២

| | |
|---|---|
| ឈ្មោះគម្រោង | កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី ២ |
| លេខគម្រោង | 47136-006 |
| ប្រទេស | ប្រទេសកម្ពុជា |
| ស្ថានភាពគម្រោង | ត្រូវបានស្នើឡើង |
| ប្រភេទ/គំរូនៃការផ្តល់ជំនួយសម្រាប់គម្រោងនេះ | ឥណទាន |
| ប្រភពមូលនិធិ/ចំនួន | **ឥណទាន៖ កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ ទី២** |

| | |
|---|---|
| ការផ្តល់ឥណទានសម្បទាន ដោយប្រើប្រាស់ធនធានមូលធនធម្មតា/មូលនិធិអភិវឌ្ឍន៍អាស៊ី | ១៥,០០ លានដុល្លារ |
| ការផ្តល់ឥណទានសម្បទាន ដោយប្រើប្រាស់ធនធានមូលធនធម្មតា/មូលនិធិអភិវឌ្ឍន៍អាស៊ី | ៣៥,០០ លានដុល្លារ |

| | |
|---|---|
| របៀបវារៈជាយុទ្ធសាស្ត្រ | កំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នា |
| កត្តាជម្រុញឱ្យមានការផ្លាស់ប្តូរ | អភិបាលកិច្ច និងការអភិវឌ្ឍសមត្ថភាព |
| វិស័យ/អនុវិស័យ | **អប់រំ** - ការអភិវឌ្ឍវិស័យអប់រំ - មធ្យមសិក្សា |
| សមធម៌ និងការបញ្ជ្រាបយេនឌ័រ | ការបញ្ជ្រាបយេនឌ័រ |
| ពិពណ៌នា | កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី ២ (USESDP 2) ដែលត្រូវបានស្នើឡើងនេះ ជាផ្នែកមួយនៃការគាំទ្រជាដំណាក់កាលៗរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដើម្បីអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពខ្ពស់ តាមរយៈការបង្កើនប្រសិទ្ធភាពនៃការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ។ កម្មវិធីនេះ ត្រូវបានរៀបចំឡើងផ្អែកទៅតាម និងបំពេញបន្ថែមកម្មវិធីអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី ១ (USESDP 1) ដែលកំពុងអនុវត្ត។ កម្មវិធីនេះមានគោលបំណងប្រើប្រាស់សមធម៌យេនឌ័រ ជាប្រធានបទមួយផងដែរ។ ក្របខ័ណ្ឌរៀបចំ និងពិនិត្យតាមដានបឋម មានបង្ហាញជូនក្នុងឧបសម្ព័ន្ធទី ១ ហើយដើមឈើបញ្ហា មានបង្ហាញជូនក្នុងឧបសម្ព័ន្ធទី ២។ |
| សនិទានភាពនៃគម្រោង និងទំនាក់ទំនងជាមួយយុទ្ធសាស្ត្ររបស់ប្រទេស/ថ្នាក់តំបន់ | បញ្ហានៃការអភិវឌ្ឍៈ ការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ បំពេញតួនាទីយ៉ាងសំខាន់ក្នុងការបំពាក់បំប៉នយុវជននូវជំនាញ សមត្ថភាព និងចំណេះដឹងសមស្រប ដើម្បីឱ្យពួកគេអាចទទួលបានភាគផល និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់ប្រទេស។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាខ្វះខាតពាក់ព័ន្ធនឹងលទ្ធផលនៅកម្រិតអប់រំមធ្យមសិក្សាទុតិយភូមិ នៅតែបន្តកើតមាន បានក្លាយជាឧបសគ្គសម្រាប់វិស័យអប់រំ និងសក្តានុពលកំណើនរយៈពេលមធ្យមនៃសេដ្ឋកិច្ចរបស់ប្រទេសនេះ។ អត្រារួមនៃការសិក្សា នៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងឆ្នាំសិក្សា ២០១៦-២០១៧ នៅមានកម្រិតទាប ត្រឹម ២៦,៥%។ ក្នុងឆ្នាំសិក្សា ២០១៥-២០១៦ សិស្សមធ្យមសិក្សាទុតិយភូមិ ១៩% បានបោះបង់ចោលការសិក្សា ខណៈ |

ពេលដែលតិចជាង ២១% បានបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិ។ អត្រាប្រឡងជាប់ការប្រឡងថ្នាក់ទី ១២ មានត្រឹមតែ ៦២,១៨% តែប៉ុណ្ណោះ ហើយអត្រានេះរឹតតែទាបទៅទៀត សម្រាប់បណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រ។ សិស្សជាច្រើននាក់ដែលបានរៀនចប់កម្រិតមធ្យមសិក្សាទុតិយភូមិ ពុំបានត្រៀមខ្លួនបន្តការសិក្សា ឬទទួលបានការបណ្តុះបណ្តាលជំនាញ ដើម្បីបំពេញទៅតាមលក្ខខណ្ឌតម្រូវរបស់និយោជកនោះឡើយ។ ខណៈពេលដែលមានការសម្រេចបាននូវយុត្តិភាពយេនឌ័រជារួមនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ភាពខុសប្លែកគ្នានៅតែបន្តមានរវាងតំបន់ប្រជុំជន និងតំបន់ជនបទ និងរវាងខេត្តមួយ និងខេត្តមួយទៀត។

ឧបសគ្គដែលនាំឱ្យរាំងស្ទះដល់ការអភិវឌ្ឍវិស័យនេះ៖ លទ្ធភាពទទួលបានការអប់រំ គុណភាព និងភាពឆ្លើយតបនៅមានកម្រិតទាប និងសមត្ថភាពរៀបចំផែនការគ្រប់គ្រង និងផ្តល់សេវាអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិនៅមានកម្រិតខ្សោយ គឺជាឧបសគ្គដែលរាំងស្ទះដល់ការអភិវឌ្ឍវិស័យអប់រំមធ្យមសិក្សាទុតិយភូមិ។

លទ្ធភាពទទួលបានការអប់រំនៅកម្រិតមធ្យមសិក្សាទុតិយភូមិ មានកម្រិតទាប៖ ចំណាយឱកាសខ្ពស់នៃការចូលរៀនក្នុងចំណោមសិស្ស ដែលមានជីវភាពក្រីក្រ គឺជាឧបសគ្គផ្នែកខាងតម្រូវការដ៏ធំមួយ ដែលរារាំងដល់ការចូលរៀន និងការបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ។ នៅតាមតំបន់ជួបការលំបាក វត្តមានសិស្សក្នុងកម្រិតមួយទាប កើតឡើងដោយសារបញ្ហាខ្វះគ្រូ។ រដ្ឋាភិបាលបានចាត់ទុកការដោះស្រាយបញ្ហាក្នុងការទទួលបានការអប់រំទាំងនេះ ថាជាអាទិភាពខ្ពស់មួយ ដោយបានដាក់ចេញនូវគំនិតផ្តួចផ្តើមគោលនយោបាយ និងការប្តេជ្ញាចិត្តផ្នែកថវិកា ចាប់តាំងពីឆ្នាំ ២០១៦ មក។ កម្មវិធី USESDP1 បានគាំទ្រដល់សកម្មភាពគោលនយោបាយ ដើម្បីបង្កើនការចូលរៀន និងបច្ចុប្បន្ននេះ កំពុងផ្តល់ការគាំទ្រដល់ការវិនិយោគពាក់ព័ន្ធនានាបន្ថែមទៀត ក្រោមក្របខ័ណ្ឌនៃគម្រោងនេះ រហូតដល់ឆ្នាំ ២០២១។

ការខ្វះគ្រូដែលមានសមត្ថភាព៖ ការខ្វះគ្រូដែលមានសមត្ថភាព និងគ្រូឧទ្ទេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ គឺជាឧបសគ្គដ៏ធំមួយ ដែលរារាំងដល់ការសម្រេចលទ្ធផលនៃការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិឱ្យបានល្អប្រសើរ។ ក្នុងចំណោមគ្រូ នៅកម្ពុជាប្រាំនាក់ មានជាងបួននាក់ ដែលពុំមានសញ្ញាបត្របរិញ្ញាបត្រ។ គ្រូជាច្រើននាក់ពុំបានត្រៀមខ្លួន ដើម្បីបង្រៀនមុខវិជ្ជាឯកទេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិនោះឡើយ។ កម្មវិធីបណ្តុះបណ្តាលគ្រូពុំបានឆ្លើយតបគ្រប់គ្រាន់ចំពោះបញ្ហាខ្វះ

ការយល់ដឹងពីខ្លឹមសារមេរៀន ឬចំណេះដឹងអំពីវិធីសាស្ត្រគរុកោសល្យ ដើម្បីលើកកម្ពស់ការរៀនសូត្រ និងចំណាប់អារម្មណ៍របស់សិស្សនោះឡើយ។ ក្រៅតែពីការត្រៀមរៀបចំគ្រូពុំទាន់បានល្អប្រសើរ គ្រូ និងគ្រូឧទ្ទេសបច្ចុប្បន្ននេះក៏មានឱកាសអភិវឌ្ឍន៍វិជ្ជាជីវៈតិចតួច ដើម្បីបង្កើនចំណេះដឹង អំពីខ្លឹមសារគរុកោសល្យរបស់ខ្លួនផងដែរ។ កង្វះគ្រូដែលមានសមត្ថភាពអាចពន្យល់មួយផ្នែកថាកើតឡើងដោយសារការលំបាកក្នុងការទាក់ទាញនិស្សិតបញ្ចប់ការសិក្សា ដែលទទួលបានលទ្ធផលល្អប្រសើរជាងគេ ឱ្យចាប់យកអាជីពជាគ្រូបង្រៀន។ ការពង្រាយគ្រូនៅតែជាបញ្ហាប្រឈម ដោយសារមានគ្រូដែលមានសមត្ថភាពតិចតួច ជាពិសេស គ្រូស្រី នៅតំបន់ជួបការលំបាក។ ភាគរយនៃគ្រូស្រី នៅកម្រិតមធ្យមសិក្សាទុតិយភូមិ (៣០,៦%) នៅមានកម្រិតទាបខ្លាំង។

**ស្តង់ដាកម្មវិធីសិក្សា និងការវាយតម្លៃនៅមានគុណភាព និងភាពឆ្លើយតបក្នុងកម្រិតទាបៈ សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិជាច្រើននាក់ ពុំបានទទួលជំនាញ** ឬសមត្ថភាព ដែលចាំបាច់នោះឡើយ សូម្បីតែបន្ទាប់ពីពួកគេបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ។ ក្រៅពីបញ្ហាគុណភាពគ្រូ ការពុំមានការកំណត់ស្តង់ដាសេវាអប្បបរមាសម្រាប់ធនធានជាមូលដ្ឋាន (ឧទាហរណ៍ មន្ទីរពិសោធន៍ រោងជាង និងឧបករណ៍សម្ភារៈ) ដែលមានសារៈសំខាន់សម្រាប់ការបង្រៀន និងរៀនមុខវិជ្ជាឯកទេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ធ្វើឱ្យបញ្ហាអសមធម៌នៃគុណភាពបង្រៀន និងរៀនតាមសាលារៀននានា រឹតតែមានសភាពធ្ងន់ធ្ងរថែមទៀត។ ការខ្វះគោលនយោបាយជាតិស្តីពីការវាយតម្លៃការសិក្សា ដើម្បីវាស់វែងការរៀនសូត្ររបស់សិស្ស គឺជាឧបសគ្គរាំងដល់ការលើកកម្ពស់ខ្លឹមសារមេរៀន និងគរុកោសល្យ។ ប្រព័ន្ធអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ ក៏ជួបនឹងការលំបាក ដោយសារតែការភ្ជាប់ទំនាក់ទំនងជាមួយដៃគូវិស័យឯកជន នៅមានកម្រិតខ្សោយ ដែលទំនាក់ទំនងបែបនេះ អាចជួយបង្កើនភាពឆ្លើយតបនៃការអប់រំនៅកម្រិតនេះ ជាមួយនឹងទីផ្សារការងារ។

សមត្ថភាពរៀបចំផែនការគ្រប់គ្រង និងផ្តល់សេវានៅមានកម្រិតខ្សោយៈ ថវិកាពុំគ្រប់គ្រាន់សម្រាប់ការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ បង្កជាឧបសគ្គដល់ការផ្តល់ធនធានសំខាន់ៗ ដើម្បីបង្កើនសមត្ថភាពរបស់សិស្សខាងមុខវិជ្ជាឯកទេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ សាលាមធ្យមសិក្សាទុតិយភូមិតិចជាង ១០% ប៉ុណ្ណោះ ដែលមានសម្ភារៈរូបវន្តវិទ្យាសាស្ត្រ។ សមត្ថភាពរបស់គណៈគ្រប់គ្រងសាលារៀននៅមានកម្រិតទាប ក្នុងការរៀបចំ និងអនុវត្តផែនការកែលម្អសាលារៀន និងជំរុញឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធ ក៏បង្កការលំបាកដល់ការវិភាគ និងការប្រើ

ប្រាស់ធនធានឱ្យមានប្រសិទ្ធភាពផងដែរ (ឧបសម្ព័ន្ធបន្ថែមទី ១)។ គម្លាតយេនឌ័រនៅតែបន្តមានក្នុងកម្រិតអប់រំមធ្យមសិក្សាទុតិយភូមិ (ឧបសម្ព័ន្ធទី ៤)។ សមត្ថភាពបញ្ជ្រាបយេនឌ័រប្រកបដោយប្រសិទ្ធភាព និងជាពិសេសការអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ (GMSP) ២០១៦-២០២០ ឱ្យបានពេញលេញក្នុងវិស័យអប់រំនៅមានកម្រិតនៅឡើយ (លេខយោងលេខ ៨)។

ការចូលរួមរបស់ ADB គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥-២០២៥ របស់រដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ (អាចនឹងបន្តរហូតដល់ឆ្នាំ ២០២០) និងអាទិភាព ដែលត្រូវបានដាក់ចេញក្នុងចក្ខុវិស័យអប់រំ ២០៣០ គឺជាក្របខ័ណ្ឌគោលនយោបាយ និងជាផែនទីបង្ហាញផ្លូវសម្រាប់ការចូលរួមសហការរបស់ ADB ក្នុងវិស័យអប់រំមធ្យមសិក្សាទុតិយភូមិនៅក្នុងរយៈពេលមធ្យម។ កំណែទម្រង់វិស័យ ដែលត្រូវបានកំណត់ ត្រូវការពេលដើម្បីអនុវត្ត និងបង្ហាញឱ្យឃើញពីលទ្ធផលលើការអភិវឌ្ឍ ដោយសារតែលទ្ធផលដែលសម្រេចនាពេលបច្ចុប្បន្ននៅមានកម្រិតទាប។ ការចូលរួមក្នុងវិស័យអប់រំមធ្យមសិក្សាទុតិយភូមិរបស់ ADB រួមមាន ការគាំទ្រ ជាយុទ្ធសាស្ត្រជាជំហានៗ ពីរយៈពេលមធ្យមទៅរយៈពេលវែង ដើម្បីកសាងមូលដ្ឋានគ្រឹះ សម្រាប់កំណែទម្រង់ និងជួយឱ្យកំណែទម្រង់ទាំងនេះចាក់ឫសឱ្យបានរឹងមាំ និងបង្ហាញលទ្ធផល។ កម្មវិធី USESDP 1 ដែលអន្តរាគមន៍ដំបូងរបស់ ADB ផ្តោតលើវិស័យអប់រំមធ្យមសិក្សាទុតិយភូមិ កំពុងគាំទ្រដល់រដ្ឋាភិបាលក្នុងការឆ្លើយតបចំពោះឧបសគ្គ ដែលនាំឱ្យមានការចូលរៀនក្នុងកម្រិតទាប។ កម្មវិធីនេះ ក៏ផ្តល់ការគាំទ្រដំបូងៗ ដល់កំណែទម្រង់សំខាន់ៗ ដើម្បីបង្កើនគុណភាព ភាពឆ្លើយតប និងសមត្ថភាពគ្រប់គ្រង ដូចជា ការរៀបចំគោលនយោបាយគ្រូបង្រៀន ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងការពង្រឹងការអប់រំមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យាជាដើម។ ដើម្បីបង្កើនផលជះរយៈពេលវែង លើលទ្ធផលនៃការសិក្សា បន្ទាប់ពីកំណែទម្រង់ ដែលផ្តោតលើគុណភាព ភាពឆ្លើយតប និងសមត្ថភាពគ្រប់គ្រង ចាំបាច់ត្រូវមានការបន្តកំណែទម្រង់បន្ថែមទៀត ដែលត្រូវអនុវត្តភ្លាមៗ ក្រោមក្របខ័ណ្ឌនៃកម្មវិធី USESDP2 នេះ។ កម្មវិធីទាំងពីរនេះ ត្រូវបានតម្រឹមស្របគ្នាជាមួយនឹងយុទ្ធសាស្ត្រស្តីពីភាពជាដៃគូប្រចាំប្រទេសរបស់ ADB ២០១៤-២០១៨។ ការគាំទ្រដំណាក់កាលទី ៣ សម្រាប់ការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងឆ្នាំ ២០២១ នឹងឆ្លើយតបចំពោះបញ្ហាដែលនៅសេសសល់ ដើម្បីបន្តលើកកម្ពស់លទ្ធផលសិក្សា និងសមត្ថភាពអាចរកការងារធ្វើរបស់សិស្ស។ ស្របតាមទិសដៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្មី ២០១៩-២០២៣ និងចក្ខុវិស័យ ២០៣០ របស់រដ្ឋាភិបាល វិស័យដែលកម្មវិធីនេះ

គ្រោងនឹងចូលរួម រួមមាន កំណែទម្រង់ ដើម្បីបង្កើនការទទួលបានជំនាញ និង ចំណេះដឹងដែលត្រូវការចាំបាច់ ក្នុងសតវត្សរ៍ទី ២១។ កំណែទម្រង់នេះ រួមមាន នវានុវត្តន៍ និងការកែលម្អទំនាក់ទំនងជាមួយការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការអប់រំកម្រិតឧត្តមសិក្សា។

កម្មវិធីអភិវឌ្ឍន៍វិស័យ៖ មេរៀនដែលទទួលបានពីកម្មវិធីអភិវឌ្ឍន៍វិស័យ ដែល ADB អនុវត្តកន្លងមកនៅកម្ពុជា បង្ហាញឱ្យឃើញពីប្រសិទ្ធផលនៃការបញ្ចូលកម្មវិធីផ្អែកតាមគោលនយោបាយ ជាមួយនឹងសមាសភាគវិនិយោគ ដើម្បីឱ្យមានការឆ្លើយតបគ្រប់ជ្រុងជ្រោយ ចំពោះបញ្ហាចំណុចខ្វះខាត និងអាទិភាពរបស់វិស័យ។ ដូច្នេះ កម្មវិធី USESDP 2 នេះ ត្រូវបានស្នើឡើង ជាកម្មវិធីអភិវឌ្ឍន៍វិស័យ។ កម្មវិធីនឹងបន្តគាំទ្រដល់កំណែទម្រង់គោលនយោបាយសំខាន់ៗ និងឆ្លើយតបចំពោះតម្រូវការវិនិយោគមិនទាន់បានបំពេញនៅឡើយ ជាពិសេសផ្នែកគុណភាព និងភាពឆ្លើយតបនៃការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ។ សមាសភាគគោនយោបាយ នឹងដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយជាតិ ខណៈពេលដែលសមាសភាគវិនិយោគនឹងគាំទ្រដល់វិធានការ ដើម្បីអនុវត្តក្របខ័ណ្ឌគោលនយោបាយនេះ។ គេរំពឹងថា កំណែទម្រង់គោលនយោបាយជាច្រើន ក្នុងចំណោមកំណែទម្រង់គោលនយោបាយទាំងនេះ នឹងនាំឱ្យមានការចំណាយហិរញ្ញវត្ថុសន្ទឹកសន្ធាប់ ដែលដំបូងៗ អាចទទួលបានការគាំទ្រ តាមរយៈសមាសភាគវិនិយោគ។ ខណៈពេលដែល ADB គឺជាដៃគូអភិវឌ្ឍន៍តែមួយគត់ ដែលផ្តោតលើការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ ក្រុមការងាររបស់គម្រោងនឹងបន្តជានាឱ្យមានការសម្របសម្រួលឱ្យបានរឹងមាំជាមួយដៃគូអភិវឌ្ឍន៍ដែលកំពុងធ្វើការងារជុំវិញកំណែទម្រង់វិស័យអប់រំ។

---

| | |
|---|---|
| ផលជះរយៈពេលវែង | ធនធានមនុស្សដែលមានគុណភាពខ្ពស់ ត្រូវបានអភិវឌ្ឍ |
| លទ្ធផលរយៈពេលមធ្យម | ប្រសិទ្ធភាពនៃប្រព័ន្ធអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិត្រូវបានបង្កើន |
| លទ្ធផលរយៈពេលខ្លី | គុណភាពរបស់គ្រូនៅតាមសាលាមធ្យមសិក្សាទុតិយភូមិត្រូវបានបង្កើន<br><br>គុណភាព និងភាពឆ្លើយតបចំពោះតម្រូវការក្នុងទីផ្សារការងារនៃការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ ត្រូវបានបង្កើន |

| | | |
|---|---|---|
| | សមត្ថភាពស្ថាប័នក្នុងការរៀបចំផែនការគ្រប់គ្រង និងផ្តល់ការអប់រំមធ្យមសិក្សាទុតិយភូមិ ត្រូវបានពង្រឹង | |
| ទីតាំងភូមិសាស្ត្រ | | |
| **ប្រភេទនៃកិច្ចការពារ** | | |
| បរិស្ថាន | | C |
| ការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត | | C |
| ជនជាតិដើមភាគតិច | | B |
| **សង្ខេបអំពីបញ្ហាបរិស្ថាន និងបញ្ហាសង្គម** | | |
| ទិដ្ឋភាពផ្នែកបរិស្ថាន | | |
| ការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត | | |
| ជនជាតិដើមភាគតិច | | |
| **ការប្រាស្រ័យទាក់ទង ការចូលរួម និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ** | | |
| ក្នុងកំឡុងពេលរៀបចំគម្រោង | | |
| ក្នុងកំឡុងពេលអនុវត្តគម្រោង | | |

| | |
|---|---|
| មន្ត្រីធនាគារអភិវឌ្ឍន៍អាស៊ីដែលទទួលខុសត្រូវ | Perez, Lynnette |
| នាយកដ្ឋានធនាគារអភិវឌ្ឍន៍អាស៊ីដែលទទួលខុសត្រូវ | នាយកដ្ឋានអាស៊ីអាគ្នេយ៍ |
| ផ្នែករបស់ធនាគារអភិវឌ្ឍន៍អាស៊ីដែលទទួលខុសត្រូវ | ផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស និងសង្គមនៃនាយកដ្ឋានអាស៊ីអាគ្នេយ៍ |
| ទីភ្នាក់ងារប្រតិបត្តិ | ក្រសួងអប់រំ យុវជន និងកីឡា<br>អគារ ១៨៨ មហាវិថី នរោត្តម<br>រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |

## កាលវិភាគ

| | |
|---|---|
| ការអនុម័តលើទស្សនទាន | ថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១៧ |
| បេសកកម្មស្វែងរកការពិត | ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៨ ដល់ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៨ |
| កិច្ចប្រជុំត្រួតពិនិត្យឡើងវិញរបស់ថ្នាក់គ្រប់គ្រង ( MRM ) | ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៨ |
| ការអនុម័ត | |
| បេសកកម្មត្រួតពិនិត្យលើកចុងក្រោយ | - |
| បច្ចុប្បន្នភាព PDS លើកចុងក្រោយ | ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៧ |

| | |
|---|---|
| គេហទំព័ររបស់គម្រោង | https://www.adb.org/projects/47136-006/main |
| សំណើសុំព័ត៌មាន | http://www.adb.org/forms/request-information-form?subject=47136-006 |
| កាលបរិច្ឆេទនៃការបង្កើតឯកសារ | ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១៨ |

ទិន្នន័យគម្រោង (PDS) រួមមានព័ត៌មានសង្ខេបអំពីគម្រោង ឬកម្មវិធី៖ អាស្រ័យដោយ PDS គឺជាការងារមួយដែលកំពុងបន្ត ដូច្នេះព័ត៌មានមួយចំនួនអាចមិនត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងបឋម ប៉ុន្តែ ព័ត៌មានទាំងនោះនឹងត្រូវយកមកបន្ថែមនៅពេលដែលមានព័ត៌មាន។ ព័ត៌មានអំពីសំណើគម្រោង គឺជាព័ត៌មានដែលអាចមានការប្រែប្រួល និង ជាព័ត៌មានបណ្តោះអាសន្នតែប៉ុណ្ណោះ។

ធនាគារអភិវឌ្ឍន៍អាស៊ី ផ្តល់ព័ត៌មាននៅក្នុងទិន្នន័យគម្រោងនេះ (PDS) ដើម្បីជាធនធានសម្រាប់អ្នកប្រើប្រាស់តែប៉ុណ្ណោះ ដោយពុំមានការធានាក្នុងទម្រង់ណាមួយឡើយ។ បើទោះបីជាធនាគារអភិវឌ្ឍន៍អាស៊ី ព្យាយាមផ្តល់មាតិកាប្រកបដោយគុណភាពខ្ពស់ក៏ដោយ ប៉ុន្តែព័ត៌មានត្រូវបានផ្តល់ជូន "ក្នុងលក្ខណៈមួយ" ដែលពុំមានការ ធានាក្នុងទម្រង់ណាមួយទេ មិនចំពោះថាជាការធានាដែលមានការបញ្ជាក់ច្បាស់លាស់ ឬ ជាការធានាដែលបង្កប់អត្ថន័យឡើយ រាប់បញ្ចូលទាំងការធានាដែលពុំមានការកំណត់ចំពោះភាពសមស្របសម្រាប់ទីផ្សារ ភាពសមស្របសម្រាប់គោលបំណងជាក់លាក់ណាមួយ និង ការមិនរំលោភបំពាន។ ជាពិសេស ធនាគារអភិវឌ្ឍន៍អាស៊ី មិនផ្តល់ការធានា ឬភាពជាតំណាងណាមួយទៅលើសុក្រឹត្យភាព ឬ ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មាននេះឡើយ។